**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីប្រកាសព័ត៌មាន

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនដំណឹងដល់សាធារណជន ជាពិសេស កម្មករនិយោជិត និងអង្គការវិជ្ជាជីវៈទាំងអស់ ជ្រាបថា ក្នុងសុឆន្ទៈលើកកម្ពស់ និងការពារសិទ្ធិ ផលប្រយោជន៍ និងលក្ខខណ្ឌការងាររបស់កម្មករនិយោជិត គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០១៦នេះ កម្ពុជាជាប្រទេសតែមួយគត់ក្នុងតំបន់ ដែលបានផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិខាងការងារ (International Labour Conventions) ច្រើនជាងគេរហូតដល់ទៅ១៣ ដែលក្នុងនោះមានអនុសញ្ញាស្នូលទាំង៨ មានជាអាទិ៍៖

១-អនុសញ្ញាលេខ២៩ ស្តីពីការងារដោយបង្ខំ

២-អនុសញ្ញាលេខ៨៧ ស្តីពីសេរីភាពនៃសមាគម និងការការពារសិទ្ធិនៃការបង្កើតសមាគម

៣-អនុសញ្ញាលេខ៩៨ ស្តីពីការអនុវត្តគោលការណ៍ស្តីអំពីសិទ្ធិនៃការបង្កើតសមាគម និងសិទ្ធិនៃការចរចាជាសមូហភាព

៤-អនុសញ្ញាលេខ១០០ស្តីពីប្រាក់ឈ្នួលស្មើគ្នាសម្រាប់កម្មករនិយោជិតបុរស-ស្ត្រីចំពោះការងារមានតម្លៃស្មើគ្នា

៥-អនុសញ្ញាលេខ១០៥ស្តីពីការលុបបំបាត់ការងារដោយបង្ខំ

៦-អនុសញ្ញាលេខ១១១ស្តីពីការរើសអើងក្នុងការងារ និងមុខរបរ

៧-អនុសញ្ញាលេខ១៣៨ស្តីពីការកំរិតអាយុអប្បបរមាសម្រាប់ការចូលធ្វើការងារ

៨-អនុសញ្ញាលេខ១៨២ ស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ។

ក្រៅពីអនុសញ្ញាអន្តរជាតិខាងការងារ ដែលបានផ្តល់សច្ចាប័នខាងលើនេះ កម្ពុជាក៏បានធ្វើកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទជាមួយអង្គការអន្តរជាតិខាងការងារ ដើម្បីបញ្ចូលខ្លឹមសារដែលមានចែងនៅក្នុងអនុសញ្ញាអន្តរជាតិខាងការងារផ្សេងទៀត ទៅក្នុងច្បាប់ និងបទបញ្ញត្តិរបស់កម្ពុជាផងដែរ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងធ្វើការសិក្សាស្រាវជ្រាវ ពិនិត្យលទ្ធភាពផ្តល់សច្ចាប័នដល់អនុសញ្ញាអន្តរជាតិខាងការងារផ្សេងទៀត ដូចជា អនុសញ្ញាលេខ១៨៣ និង១៨៩។ល។ ស្របទៅតាមតម្រូវការជាក់ស្តែងរបស់កម្ពុជា និងបរិបទក្នុងតំបន់។

សេចក្តីដូចបានជម្រាបជូននេះ សូម សាធារណជន កម្មករនិយោជិត និងអង្គការវិជ្ជាជីវៈទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩